**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**

លេខ :១៦៤/០០២/២០០៩

ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០០៩

**សេចក្តីសម្រេច**

លេខ :១០៥/០០១/២០០៩ កបធ.ច

ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០០៩

## ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានឃើញលិខិតលេខ ១៦៨ លស ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០០៩ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញបកស្រាយមាត្រា ១៧ និងមាត្រា ១៨ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ បានទទួលនៅថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០០៩ វេលាម៉ោង ១៦ និង ៥០ នាទី ។

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា ស្របតាមមាត្រា១៣៦ថ្មី មាត្រា១៤១ថ្មី នៃរដ្ឋធម្មនុញ្ញ និងមាត្រា១៥ថ្មី មាត្រា១៨ថ្មី នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ក្រុមប្រឹក្សាធម្មនុញ្ញ អាចទទួលសំណើសុំបកស្រាយ លេខ ១៦៨ លស ចុះថ្ងៃទី១៩ ខែ កុម្ភៈ ឆ្នាំ ២០០៩ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី យកមកពិនិត្យបាន
- យល់ឃើញថា បទបញ្ញត្តិនៃមាត្រា ១៧ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ត្រូវបានបកស្រាយថា ទាំងមន្ត្រីរាជការស៊ីវិល ទាំងយោធា ដែលកំពុងបំពេញមុខងារជាសកម្ម គ្មានសិទ្ធិជាបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាបានទេ មានន័យម្យ៉ាងទៀតថា មន្ត្រីរាជការស៊ីវិល និង យោធា មិនអាចធ្វើការងាររបស់ខ្លួនផង និងជាបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាផងបានទេ ។ ពាក្យថា **" មន្ត្រីរាជការស៊ីវិល "** រួមមាន មន្ត្រីរាជការក្នុងក្របខណ្ឌនីតិបញ្ញត្តិ ក្របខណ្ឌនីតិប្រតិបត្តិ ក្របខណ្ឌតុលាការ និងក្របខណ្ឌពិសេសផ្សេងទៀត
- យល់ឃើញថា តាមស្មារតីនៃមាត្រា ៣៤ ថ្មី នៃរដ្ឋធម្មនុញ្ញ ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ អាចឈរឈ្មោះឱ្យគេបោះឆ្នោត ។ បទបញ្ញត្តិបន្ថយសិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោត ត្រូវចែងក្នុងច្បាប់បោះឆ្នោត
- យល់ឃើញថា ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ពុំបានហាមឃាត់ដាច់ខាតមិនឱ្យឈរឈ្មោះឱ្យគេបោះឆ្នោតនោះទេ។ ប្រសិនបើមន្ត្រីរាជការស៊ីវិល និងយោធាទាំងនោះ មានបំណងចង់ឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា សាមីខ្លួនត្រូវតែបំពេញលក្ខខណ្ឌដែលមានចែងក្នុងបទបញ្ញត្តិនៃមាត្រា ១៨ នៃច្បាប់នេះ
- យល់ឃើញថា បទបញ្ញត្តិនៃមាត្រា១៨ ដែលចែកជា ៣ វាក្យខ័ណ្ឌ ត្រូវបានបកស្រាយដូចខាងក្រោមនេះ÷

ក/-បទបញ្ញត្តិនៃវាក្យខ័ណ្ឌទី ១ មានន័យថា ទាំងមន្ត្រីរាជការស៊ីវិល ទាំងយោធា ដែលមានបំណងឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ត្រូវដាក់ពាក្យសុំច្បាប់ឈប់ពិសេសយ៉ាងតិចប្រាំពីរ (០៧) ថ្ងៃ មុនថ្ងៃបើកការឃោសនាបោះឆ្នោត រហូតដល់ថ្ងៃប្រកាសលទ្ធផលនៃការបោះឆ្នោតជាផ្លូវការ ។ ពាក្យថា **" ដាក់ពាក្យសុំច្បាប់ឈប់ពិសេសយ៉ាងតិចប្រាំពីរ(០៧)ថ្ងៃ មុនថ្ងៃបើកការឃោសនាបោះឆ្នោតរហូតដល់ថ្ងៃប្រកាសលទ្ធផលនៃការបោះឆ្នោតជាផ្លូវការ "** មានន័យថា ដាក់ពាក្យសុំច្បាប់ឈប់សម្រាកពីការងារតែប៉ុណ្ណោះ មិនមែនមានន័យថា ដាក់ពាក្យសុំលាលែងពីមុខងារ ឬពីមុខតំណែងឡើយ ។ បទបញ្ញត្តិនេះមានន័យម្យ៉ាងទៀតថា មន្ត្រីរាជការស៊ីវិល និងយោធាដែលចង់ស្នើជាបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ត្រូវសុំការអនុញ្ញាតអវត្តមានពីការងារ ក្នុងរយៈពេលដូចបានកំណត់ខាងលើ ។

ខ/-បទបញ្ញត្តិនៃវាក្យខ័ណ្ឌទី ២ មានន័យថា សាមីខ្លួនជាប់ឆ្នោត ត្រូវធ្វើពាក្យទៅក្រសួង ឬ ស្ថាប័នរបស់ខ្លួន សុំទៅបម្រើការងារក្រៅក្របខ័ណ្ឌដើម ក្នុងរយៈពេលនៃអាណត្តិរបស់ក្រុមប្រឹក្សាតែប៉ុណ្ណោះ ។ ម្យ៉ាងទៀតក្នុងរយៈពេលនៃអាណត្តិនោះ សាមីខ្លួនមានសិទ្ធិឡើងថ្នាក់ ឬ ឋានន្តរសក្តិ និងរក្សាអតីតភាពការងារសម្រាប់ទទួលសោធននិវត្តន៍ទៀតផង ។

ប្រសិនបើបេក្ខជនជាប់ឆ្នោតហើយ ហើយគ្មានបំណងចង់នៅបម្រើការងារជាសមាជិកក្រុមប្រឹក្សាទេនោះ សាមីខ្លួនត្រូវធ្វើពាក្យទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដើម្បីសុំដកបេក្ខភាពរបស់ខ្លួនចេញពីបញ្ជីឈ្មោះបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា។ ក្នុងករណីនេះ សាមីខ្លួនអាចមកកាន់ការងារដើមរបស់ខ្លួនវិញបាន។

គ/-បទបញ្ញត្តិនៃវាក្យខណ្ឌទី៣ មានន័យថា នៅពេលចប់អាណត្តិជាសមាជិកក្រុមប្រឹក្សា សាមីខ្លួនអាចត្រឡប់មកបម្រើការងារនៅក្រសួង ឬ ស្ថាប័នដើមរបស់ខ្លួនវិញបាន ប៉ុន្តែសាមីខ្លួននឹងអាចបានទទួលមុខងារ ឬ មុខតំណែងដើមរបស់ខ្លួនវិញបាននោះ គឺអាស្រ័យដោយក្រសួង ឬ ស្ថាប័នជាអ្នកសម្រេច មិនមែនសាមីខ្លួនអាចទទួលមុខងារ ឬ មុខតំណែងដើមរបស់ខ្លួនវិញ ដោយស្វ័យប្រវត្តិនោះឡើយ ។

## សម្រេច

**មាត្រា ១.-** បទបញ្ញត្តិនៃមាត្រា ១៧ និង មាត្រា ១៨ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ត្រូវបានបកស្រាយដូចមានចែងក្នុងមូលបទខាងលើ ។

**មាត្រា ២.-** សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០០៩ ក្នុងកិច្ចប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និងត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ កុម្ភៈ ឆ្នាំ ២០០៩

ឯក សំអុល